**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ ...១២១៧...ល.ជ.ណ.

ថ្ងៃ.ព្រហស្បតិ៍...៦ កើត..ខែ...អស្សុជ......ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី..០៨....ខែ..តុលា....ឆ្នាំ២០២០

## សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្តល់សេវាសវនកម្ម និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ការិយបរិច្ឆេទ២០២១ ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ ត្រឹមវេលាម៉ោង១៦:០០ល្ងាច ក្នុងមួយច្បាប់តម្លៃ ២០០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ១៣:៥០នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

បណ្ឌិត ជា វិសុទ្ធ

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ